ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*ថ្ងៃ ពុធ ៦ រោច ខែ មិគសិរ ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦*

*រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០២២*

# សេចក្តីជូនដំណឹងសម្រាប់ប្រព័ន្ធសារព័ត៌មាន

## ស្តីពី

## ជំនួបសម្តែងការគួរសម និងការជម្រាបលា របស់ឯកឧត្តម PARK Heung-Kyeong ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋកូរ៉េ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

នាព្រឹកថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០២២, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបសម្តែងការគួរសម និងជម្រាបលារបស់ឯកឧត្តម **PARK Heung-Kyeong** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋកូរ៉េ ដែលបានបញ្ចប់អាណត្តិបេសកកម្មការទូត នៅព្រះរាជាណាចក្រកម្ពុជា ។

ជាកិច្ចចាប់ផ្តើម, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានថ្លែងអំណរគុណចំពោះឯកឧត្តម **PARK Heung-Kyeong** ដែលបានខិតខំប្រឹងប្រែងអស់ពីកំលាំងកាយចិត្ត ក្នុងការបំពេញភារកិច្ចរបស់ខ្លួនក្នុងឋានៈជាឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋកូរ៉េ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេលជាង ៣ ឆ្នាំ ចាប់ពី ឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២២ ។ ក្នុងអាណត្តិរបស់ឯកឧត្តមអគ្គរដ្ឋទូត, ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ សម្រេចបាននូវសមិទ្ធផលផ្លែផ្កាជាច្រើន មានជាអាទិ៍: កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-កូរ៉េ ដែលត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០២១ និងត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋសភាកូរ៉េកាលពីថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០២២ កន្លងទៅនេះ ព្រមទាំងកិច្ចព្រមព្រៀងឥណទានសម្បទានចំនួន ៨ គម្រោង/កម្មវិធី ដែលមានទឹកប្រាក់សរុបប្រមាណ **៦៤០ លាន** ដុល្លារអាមេរិក ដោយរាប់បញ្ចូលទាំងកិច្ចព្រមព្រៀងឥណទានសម្បទានចំនួន ២ ដែលទើបត្រូវបានចុះហត្ថលេខា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** នៅវិមានសន្តិភាព កាលពី ថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ២០២២ ពោលគឺកិច្ចព្រមព្រៀងសម្រាប់គម្រោងសាងសង់ស្ពានមិត្តភាពកម្ពុជា-សាធារណរដ្ឋកូរ៉េ (ភ្នំពេញ-អរិយក្សត្រ) និងកិច្ចព្រមព្រៀងសម្រាប់គម្រោងពង្រឹងសមត្ថភាពប្រព័ន្ធបណ្តាញបញ្ជូនអគ្គិសនីនៅខេត្តព្រះសីហនុ ។

បន្ថែមពីលើនេះ, ភាគីទាំងពីរក៏បានឯកភាពនូវកញ្ចប់ឥណទានសម្បទានថ្មីមួយទៀត តាមរយៈកិច្ចសម្របសម្រួលក្របខ័ណ្ឌ ដែលមានទំហំទឹកប្រាក់ចំនួន **១ ៥០០ លាន** ដុល្លារអាមេរិក សម្រាប់ឆ្នាំ ២០២២-២០២៦ ។

ឯកឧត្តម **PARK Heung-Kyeong** បានថ្លែងអំណរគុណ និងអបអរសាទរដល់កម្ពុជា ដែលបានបំពេញតួនាទីយ៉ាងល្អប្រសើរ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្នុងនាមជាប្រធានអាស៊ាន កាលពីពេលកន្លងទៅ ព្រមទាំងអបអរសាទរចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានចាត់វិធានការដ៏មានប្រសិទ្ធភាព ប្រកបដោយភាពបុរេសកម្មក្នុងការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលអនុញ្ញាតឱ្យកម្ពុជាអាចបើកដំណើរការសកម្មភាពសង្គម-សេដ្ឋកិច្ចពេញលេញឡើងវិញលើគ្រប់វិស័យ ។ ទន្ទឹមនេះ, ឯកឧត្តមឯកអគ្គរដ្ឋទូតក៏បានសម្តែងនូវសេចក្តីរីករាយជាអនេក ចំពោះសមិទ្ធផលជាច្រើនដែលសម្រេចបានរួមគ្នា រវាងកម្ពុជា និងសាធារណរដ្ឋកូរ៉េ ជាពិសេសគម្រោងស្ពានមិត្តភាពកម្ពុជា-កូរ៉េនៅរាជធានីភ្នំពេញ ភ្នំពេញ-អរិយក្សត្រ ។

ជាមួយគ្នានេះ, ឯកឧត្តមឯកអគ្គរដ្ឋទូត បានស្នើឱ្យរាជរដ្ឋាភិបាលកម្ពុជា ពិចារណាលើការវិនិយោគបន្ថែមក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ដទៃទៀតនៅភាគខាងកើតទន្លេមេគង្គក្នុងខេត្តកណ្តាល ស្របពេលដែលស្ពានមិត្តភាពកម្ពុជា-សាធារណរដ្ឋកូរ៉េ ចាប់ផ្តើមដំណើរការសាងសង់ តាមរយៈការសិក្សាលើផែនការមេ (Master Plan) ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់នានា នៅភាគខាងកើតក្នុងភូមិសាស្ត្រខេត្តកណ្តាល ដើម្បីទាញយកអត្ថប្រយោជន៍ជាអតិបរមាពីគម្រោងស្ពានមិត្តភាពកម្ពុជា-សាធារណរដ្ឋកូរ៉េ ភ្នំពេញ-អរិយក្សត្រ ហើយភាគីកូរ៉េត្រៀមខ្លួនជាស្រេចក្នុងការផ្តល់នូវកិច្ចសហការជិតស្និទ្ធក្នុងការសិក្សារៀបចំផែនការមេនេះ តាមតម្រូវការជាក់ស្តែង ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណ និងទទួលយកនូវគំនិតផ្តួចផ្តើមដើម្បីធ្វើការសិក្សាក្នុងការរៀបចំផែនការមេ ក្នុងការវិនិយោគបន្ថែមលើបណ្តាញហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ពីតំបន់មួយទៅតំបន់មួយទៀត នៅក្នុងតំបន់ប៉ែកខាងកើតនៃរាជធានីភ្នំពេញ ក្នុងជំហានបន្តបន្ទាប់ទៀត ដើម្បីជំរុញសកម្មភាពសង្គម-សេដ្ឋកិច្ចនៅតំបន់នោះ ឱ្យរីកចម្រើនឆាប់រហ័សនាពេលអនាគត ។

ភាគីទាំងពីរក៏បានសន្យាថា នឹងបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការនានា តាមរយៈការផ្តល់ហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការ ដើម្បីរួមចំណែកលើកស្ទួយសកម្មភាពអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ពិសេស ការផ្តល់ជំនួយបច្ចេកទេសផ្សេងៗទៀត និងការគិតគូរអំពីការពង្រឹងវិស័យអប់រំ និងការសិក្សាស្រាវជ្រាវ តាមរយៈកម្មវិធីចែករំលែកចំណេះដឹង (Knowledge Sharing Program - KSP) និងវិទ្យាស្ថានអភិវឌ្ឍន៍កូរ៉េ (Korea Development Institute - KDI) ដែលយន្តការទាំងនេះអនុញ្ញាតឱ្យប្រទេសទាំងពីរ ចែករំលែកទៅវិញទៅមក នូវបទពិសោធន៍, ចំណេះដឹង និងជំនាញ ។

ជាទីបញ្ចប់, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានសម្តែងនូវអំណរគុណចំពោះភាគីកូរ៉េ និងមានជំនឿថា កិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-សាធារណរដ្ឋកូរ៉េ នឹងកាន់តែរឹងមាំ ដោយគូសបញ្ជាក់ថារដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ គឺជាដៃគូអភិវឌ្ឍន៍ទ្វេភាគីដ៏សំខាន់មួយ ក្នុងចំណោមដៃគូទ្វេភាគីធំៗដទៃទៀត ដែលតែងតែផ្តល់ការគាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងជូនពរឯកឧត្តម **PARK Heung-Kyeong** ទទួលបាននូវជោគជ័យជាបន្តបន្ទាប់ក្នុងការបំពេញភារកិច្ចថ្មីរបស់ឯកឧត្តម ។

###